ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ: ០១៣ ស/សន

# សេចក្ដីណែនាំ
## ស្ដីពី
## ការរៀបចំកិច្ចប្រជុំលើកដំបូង ដើម្បីប្រកាសសុពលភាពសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ប្រកាសឈ្មោះប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង និងការចាប់ផ្ដើមបំពេញការងារបន្ទាប់ពីការប្រជុំលើកដំបូង

អនុលោមមាត្រា១៩ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ បានកំណត់ថា "ក្នុងអំឡុងពេល ១៤ថ្ងៃ ក្រោយពីការប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោត ត្រូវចាត់ឱ្យមានការប្រជុំជាលើកដំបូងនៃក្រុមប្រឹក្សាឃុំ សង្កាត់ ក្រោមអធិបតីភាពមន្ត្រីម្នាក់ដែលចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីប្រកាសសុពលភាពសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រកាសឈ្មោះប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ជំទប់ និងចៅសង្កាត់រង"។

លើមូលដ្ឋាននៃបទបញ្ញត្តិមាត្រា ១៩ខាងលើ ដើម្បីឱ្យដំណើរការកិច្ចប្រជុំលើកដំបូងនៃក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មី ប្រព្រឹត្តទៅបានដោយរលូន និងទាន់ពេលវេលាកំណត់ ក្រសួងមហាផ្ទៃសូមធ្វើការណែនាំអំពីការរៀបចំកិច្ចប្រជុំលើកដំបូងដើម្បីប្រកាសសុពលភាពសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ប្រកាសឈ្មោះប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង និងការចាប់ផ្ដើមបំពេញការងារបន្ទាប់ពីការប្រជុំលើកដំបូង ដូចខាងក្រោម៖

**១-ការចាត់តាំងមន្ត្រីធ្វើជាអធិបតីនៃអង្គប្រជុំ**

អភិបាលរាជធានី ខេត្ត ត្រូវធ្វើការចាត់តាំងអភិបាល អភិបាលរង នៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ និងនាយករដ្ឋបាល នាយករងរដ្ឋបាល នៃសាលាក្រុង ស្រុក ខណ្ឌ ធ្វើជាអធិបតីនៃកិច្ចប្រជុំលើកដំបូងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មី ដោយឃុំ សង្កាត់នីមួយៗ មានអធិបតីម្នាក់។

ចំពោះក្រុង ស្រុក ខណ្ឌដែលមានឃុំ សង្កាត់ច្រើន ហើយពុំអាចឲ្យអភិបាល ឬអភិបាលរង នៃគណៈអភិបាល ក្រុង ស្រុក ខណ្ឌ និងនាយករដ្ឋបាល នាយករងរដ្ឋបាល នៃសាលាក្រុង ស្រុក ខណ្ឌ បែងចែកគ្នាធ្វើជាអធិបតីនៃការប្រជុំលើកដំបូងឲ្យបានគ្រប់ឃុំ សង្កាត់ តាមពេលវេលាកំណត់នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ អភិបាលក្រុង ស្រុក ខណ្ឌត្រូវធ្វើសេចក្ដីរាយការណ៍ជូនអភិបាលរាជធានី ខេត្ត ជាបន្ទាន់ ។ ក្នុងករណីនេះ អភិបាលរាជធានី ខេត្ត អាចចាត់តាំងនាយករដ្ឋបាល នាយករងរដ្ឋបាល នាយកទីចាត់ការ នាយករងទីចាត់ការ នៃសាលារាជធានី ខេត្ត ឲ្យទទួលធ្វើជាអធិបតីនៃកិច្ចប្រជុំលើកដំបូងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងរាជធានី ខេត្តរបស់ខ្លួន តាមការចាំបាច់។

អធិបតីនៃកិច្ចប្រជុំលើកដំបូងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តថ្មី មានភារកិច្ចធានាឲ្យកិច្ចប្រជុំនេះបានប្រព្រឹត្តទៅប្រកបដោយសណ្តាប់ធ្នាប់ និងមានរបៀបរៀបរយល្អ។

**២-ការកំណត់កាលបរិច្ឆេទនៃអង្គប្រជុំ**

យោងតាមមាត្រា ១៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ អភិបាលរាជធានី ខេត្ត ត្រូវចាត់ឲ្យទីចាត់ការគ្រប់គ្រងធនធានមនុស្សធ្វើកិច្ចសហការ និងសម្របសម្រួលជាមួយអភិបាលក្រុង ស្រុក ខណ្ឌ រៀបចំកាលវិភាគនៃកិច្ចប្រជុំប្រកាសសុពលភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ឱ្យបានច្បាស់លាស់ក្នុងអំឡុងពេល ១៤ថ្ងៃបន្ទាប់ពីថ្ងៃប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោត ព្រមទាំងកំណត់អំពីអ្នកដែលត្រូវធ្វើជាអធិបតីសម្រាប់កិច្ចប្រជុំដំបូងនេះនៅតាមឃុំ សង្កាត់ដែលត្រូវចាប់ផ្តើម បន្ទាប់ពីក្រសួងមហាផ្ទៃបានចេញប្រកាសសុពលភាពទទួលស្គាល់សមាសភាពសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ជំទប់ និងចៅសង្កាត់រង ដោយផ្អែកតាមលទ្ធផលនៃការបោះឆ្នោត។

**៣-ការត្រៀមលក្ខណសម្បត្តិទុកជាមុន**

ដើម្បីធានាឱ្យកិច្ចប្រជុំលើកដំបូងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មីប្រព្រឹត្តទៅដោយរលូន និងបានទាន់ពេលវេលាតាមច្បាប់កំណត់ អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់ចាស់ត្រូវត្រៀមលក្ខណៈទុកជាមុននូវការងារសំខាន់ៗមួយចំនួនដូចខាងក្រោម ៖

**៣.១-ការរៀបចំកន្លែងអង្គប្រជុំ**

យោងតាមមាត្រា២១នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ បានចែងថា "ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវប្រជុំនៅក្នុងសាលាឃុំឬសាលាសង្កាត់របស់ខ្លួន ឬក្នុងករណីចាំបាច់អធិបតីអាចជ្រើសយកទីកន្លែងណាមួយក្នុងឃុំ សង្កាត់របស់ខ្លួនដើម្បីប្រជុំ"។ ហេតុនេះ តាមឃុំ សង្កាត់នីមួយៗ ត្រូវត្រៀមរៀបចំទីកន្លែងឲ្យបានសមស្របសម្រាប់ធ្វើការប្រជុំ។

ចំពោះឃុំ សង្កាត់ដែលមានសាលាឃុំ សង្កាត់ កិច្ចប្រជុំលើកដំបូងត្រូវរៀបចំធ្វើនៅក្នុងសាលាឃុំ សង្កាត់របស់ខ្លួន។ ដោយឡែក ចំពោះឃុំ សង្កាត់ដែលគ្មានសាលាឃុំ សង្កាត់ ឬមានសាលាឃុំ សង្កាត់ដែរ ប៉ុន្តែសាលាឃុំ សង្កាត់មានសភាពចាស់ទ្រុឌទ្រោមពេក មិនអាចរៀបចំធ្វើជាកន្លែងប្រជុំបាន គួរជ្រើសយកកន្លែងសមរម្យណាមួយនៅក្នុងឃុំ សង្កាត់សម្រាប់រៀបចំជាកន្លែងប្រជុំដែលអាចជាវត្តអារាម សាលារៀន អគារសាធារណៈ.....។ល។ ដោយត្រូវសម្របសម្រួលឱ្យមានការយល់ព្រមជាមុនពីអ្នកគ្រប់គ្រងទីកន្លែងនោះ។

**៣.២-ការរៀបចំលិខិតអញ្ជើញ**

អភិបាលរាជធានី ខេត្ត ត្រូវចាត់ឲ្យអភិបាលក្រុង ស្រុក ខណ្ឌ សហការជាមួយមេឃុំ ចៅសង្កាត់អាណត្តិចាស់ ដើម្បីរៀបចំលិខិតអញ្ជើញសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលទើបជាប់ឆ្នោតថ្មី សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិចាស់ និងភ្ញៀវផ្សេងៗ ដែលត្រូវអញ្ជើញចូលរួម។

លិខិតអញ្ជើញត្រូវចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់អាណត្តិចាស់។ គ្រប់លិខិតអញ្ជើញសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានជាប់ឆ្នោតថ្មី ត្រូវតែប្រគល់ឲ្យដោយផ្ទាល់ដៃសមាជិកម្នាក់ៗ ដោយមានហត្ថលេខាទទួលផ្ទាល់ដៃ និងជូនព័ត៌មានអំពីការអញ្ជើញនេះទៅតំណាងគណបក្សនយោបាយដែលមាន

អាសនៈក្នុងក្រុមប្រឹក្សាឃុំ សង្កាត់នោះ។ ស្មៀនឃុំ សង្កាត់ ត្រូវធ្វើជាសេនាធិការក្នុងការចាត់ចែងរៀបចំ និង សម្របសម្រួលនូវរាល់កិច្ចការនានាពាក់ព័ន្ធនឹងការអញ្ជើញប្រជុំនេះ រួមទាំងការត្រៀមរៀបចំកិច្ចការ និង ឯកសារមួយចំនួនទៀត ដូចជា៖

-ការរៀបចំរបៀបវារៈ

-ការរៀបចំរបាយការណ៍សង្ខេបសម្រាប់ការផ្ទេរពីក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិចាស់ទៅ ក្រុមប្រឹក្សាអាណត្តិថ្មី

-បញ្ជីចលនទ្រព្យ អចលនទ្រព្យ ប្រាក់កាស និងបញ្ជីបុគ្គលិករបស់ឃុំ សង្កាត់អាណត្តិចាស់

-ការពិនិត្យ និងផ្ទៀងផ្ទាត់ឈ្មោះសមាជិកក្រុមប្រឹក្សាអាណត្តិថ្មី : អភិបាលរាជធានី ខេត្ត ត្រូវចាត់ ទីចាត់ការគ្រប់គ្រងធនធានមនុស្សធ្វើកិច្ចសហការជាមួយអភិបាលក្រុង ស្រុក ខណ្ឌ ធ្វើការពិនិត្យ និងផ្ទៀងផ្ទាត់ ឱ្យបានច្បាស់លាស់ថា ឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងឈ្មោះប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង ដែលបានប្រកាសជាផ្លូវការដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងឈ្មោះសមាសភាពក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានប្រកាសទទួលស្គាល់ដោយក្រសួងមហាផ្ទៃ ពិតជា ត្រឹមត្រូវតាមឈ្មោះរបស់សាមីខ្លួនក្នុងបញ្ជីបេក្ខជន និងត្រឹមត្រូវតាមច្បាប់ និងនីតិវិធីដែលបានកំណត់។

ពាក់ព័ន្ធនឹងកិច្ចការខាងលើ អភិបាលរាជធានី ខេត្ត ត្រូវចាត់ឲ្យទីចាត់ការគ្រប់គ្រងធនធានមនុស្ស មក ទំនាក់ទំនង និងទទួលយកប្រកាសស្តីពីការទទួលស្គាល់សមាសភាពសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ នៅ នាយកដ្ឋានបុគ្គលិកនៃអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ ដើម្បីចាត់ចែងបន្តឱ្យទាន់ពេលវេលា។

អភិបាលរាជធានី ខេត្ត ត្រូវចាត់ចែងធ្វើនីត្យានុកូលកម្មលើប្រកាសស្តីពីការទទួលស្គាល់សមាសភាព សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់សម្រាប់អាណត្តិថ្មីដែលចេញដោយក្រសួងមហាផ្ទៃ ដើម្បីចែកជូនដល់សមាជិក ក្រុមប្រឹក្សាឃុំ សង្កាត់ អង្គភាពពាក់ព័ន្ធ និងតម្កល់ទុកឯកសារ។

**៤-អំពីសមាសភាពនៃអង្គប្រជុំ**

កិច្ចប្រជុំលើកដំបូងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មី គួរធ្វើការអញ្ជើញសមាសភាពចូលរួម ដូច ខាងក្រោម៖

- សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានជាប់ឆ្នោតអាណត្តិថ្មីទាំងអស់
- សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិចាស់
- ស្មៀនឃុំ សង្កាត់ និងបុគ្គលិករដ្ឋបាលឃុំ សង្កាត់
- មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិនៅក្នុងឃុំ សង្កាត់
- តំណាងគណបក្សនយោបាយដែលមានអាសនៈក្នុងក្រុមប្រឹក្សា នៅឃុំ សង្កាត់ ឬក្រុង ស្រុក ខណ្ឌសាមី
- តំណាងសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ក្នុងមូលដ្ឋាន
- តំណាងគណៈកម្មាធិការ និងគណៈកម្មការនានារបស់ឃុំ សង្កាត់
- ចាស់ព្រឹទ្ធាចារ្យ តំណាងសហគមន៍ជនជាតិដើមភាគតិច (ក្នុងករណីឃុំ សង្កាត់មានជនជាតិ ដើមភាគតិច)
- ប្រជាជនមួយចំនួនតាមដែលអាចធ្វើទៅបាន។

**៥-អំពីរបៀបវារៈនៃកិច្ចប្រជុំ**

កិច្ចប្រជុំលើកដំបូងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវដំណើរការតាមរបៀបវារៈសំខាន់ៗ ដូចខាងក្រោម៖

- ប្រកាសហេតុ ប្រកាសគណៈអធិបតី និងសមាជិកដែលបានអញ្ជើញចូលរួម
- គោរពភ្លេងជាតិ នៃព្រះរាជាណាចក្រកម្ពុជា
- អានប្រកាសរបស់ក្រសួងមហាផ្ទៃស្តីពីការទទួលស្គាល់សមាសភាពសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង
- ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិចាស់ អានរបាយការណ៍សង្ខេបសម្រាប់ការផ្ទេរពីក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិចាស់ទៅក្រុមប្រឹក្សាអាណត្តិថ្មី
- ការប្រគល់ ទទួលត្រា តារាងបញ្ជីសម្ភារ ប្រាក់កាស និងឯកសារនានារបស់ឃុំ សង្កាត់ រវាងប្រធានក្រុមប្រឹក្សាអាណត្តិចាស់ និងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មី ក្នុងករណីប្រធានក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិចាស់មិនបានជាប់ឆ្នោតជាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មីបន្តទៀត។ ប្រសិនបើប្រធានក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិចាស់បានជាប់ឆ្នោតម្តងទៀតជាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មី អធិបតីនៃអង្គប្រជុំលើកដំបូង គឺជាអ្នកប្រគល់ត្រា តារាងបញ្ជីសម្ភារ ប្រាក់កាស និងឯកសារនានារបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិចាស់ ឱ្យដល់ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មី
- ការប្តេជ្ញាចិត្តរបស់ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មី
- មតិយោបល់ណែនាំរបស់អធិបតីនៃអង្គប្រជុំ។

**៦-ការរៀបចំរបាយការណ៍កិច្ចប្រជុំប្រកាសសុពលភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មី**

អភិបាលក្រុង ស្រុក ខណ្ឌត្រូវធ្វើរបាយការណ៍អំពីលទ្ធផលនៃកិច្ចប្រជុំលើកដំបូងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មីនៃក្រុង ស្រុក ខណ្ឌរបស់ខ្លួន ជូនអភិបាលរាជធានី ខេត្តជាបន្ទាន់ បន្ទាប់ពីបានបញ្ចប់កិច្ចប្រជុំលើកដំបូងនេះបានបញ្ចប់ភ្លាម។

ផ្អែកលើរបាយការណ៍របស់អភិបាលក្រុង ស្រុក ខណ្ឌ អភិបាលរាជធានី ខេត្ត ដោយមានទីចាត់ការគ្រប់គ្រងធនធានមនុស្សជាសេនាធិការ ត្រូវចាត់ចែងបូកសរុបរបាយការណ៍អំពីលទ្ធផលនៃកិច្ចប្រជុំលើកដំបូងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មី ជូនមកក្រសួងមហាផ្ទៃជាបន្ទាន់តាមថ្ងៃនីមួយៗដើម្បីធានាថា កិច្ចប្រជុំលើកដំបូងនៅគ្រប់ឃុំ សង្កាត់ ដំណើរការស្របតាមពេលវេលាដែលកំណត់ក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

**៧-អំពីកិច្ចការសំខាន់ៗដែលក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មី ត្រូវបន្តអនុវត្តបន្ទាប់ពីកិច្ចប្រជុំលើកដំបូង**

**៧.១-ការរៀបចំសេចក្តីព្រាងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់**

អនុលោមមាត្រា២០នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ បានចែងថា មុនចាប់ផ្តើមការងារក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ ត្រូវរៀបចំនិងអនុម័តបទបញ្ជាផ្ទៃក្នុងដើម្បីកំណត់នូវវិធានទាំងឡាយសម្រាប់អង្គប្រជុំ និងរបៀបរបបធ្វើការងាររបស់ខ្លួន៕

ផ្អែកលើបទប្បញ្ញត្តិខាងលើនេះ បន្ទាប់ពីកិច្ចប្រជុំប្រកាសសុពលភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់រួចមក នាថ្ងៃបន្ទាប់ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការប្រជុំដើម្បីពិនិត្យ និងរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ខ្លួនជាបន្ទាន់។

ស្មៀនឃុំ សង្កាត់ដែលជាសេនាធិការឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវទទួលខុសត្រូវនូវរាល់ការទទួល ពិនិត្យ ទុកដាក់ និងថែរក្សានូវរាល់លិខិតគ្រប់ប្រភេទរបស់រដ្ឋបាលឃុំ សង្កាត់។ ពិសេសស្មៀនឃុំ សង្កាត់ត្រូវមាន តួនាទី និងភារកិច្ចត្រូវជួយមេឃុំ ចៅសង្កាត់រៀបចំសេចក្តីព្រាងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិថ្មី ដើម្បីដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់ពិនិត្យ និងអនុម័ត។

ក្នុងការរៀបចំបទបញ្ជាផ្ទៃក្នុង ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវផ្អែកលើមូលដ្ឋានដូចខាងក្រោម៖

-សេចក្តីណែនាំលេខ ០១៤ សណន ចុះថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ២០១៧ របស់ក្រសួងមហាផ្ទៃ ស្តីពី ការរៀបចំបទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សាឃុំ សង្កាត់។

-បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិចាស់ : ដោយផ្អែកលើរបាយការណ៍អំពីការអនុវត្ត បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាអាណត្តិចាស់ ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មីត្រូវរៀបចំបទបញ្ជាផ្ទៃក្នុងមួយ ដែលមានលក្ខណៈល្អប្រសើរ សំដៅលើកកម្ពស់ប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាពក្នុងកិច្ចប្រជុំ និង របៀបរបបការងាររបស់ខ្លួន។

-ក្រុមប្រឹក្សាត្រូវធ្វើការពិភាក្សា និងអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ស្របតាមគោលការណ៍ បែបបទ និងនីតិវិធី ដូចមានចែងក្នុងសេចក្តីណែនាំលេខ ០១៤ សណន ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៧ របស់ ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំបទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សាឃុំ សង្កាត់។

-បទបញ្ជាផ្ទៃក្នុងដែលក្រុមប្រឹក្សាឃុំ សង្កាត់បានអនុម័ត និងចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាឃុំ សង្កាត់រួចហើយ ត្រូវថតចម្លងចំនួនមួយច្បាប់ ជូនអភិបាលរាជធានី ខេត្ត ក្នុងរយៈពេលយ៉ាងយូរ០៥ថ្ងៃ បន្ទាប់ពីថ្ងៃអនុម័ត ដើម្បីធ្វើការពិនិត្យនីត្យានុកូលភាព។

**៧.២-ការបន្តការងារគ្រប់គ្រង និងដឹកនាំរដ្ឋបាលឃុំ សង្កាត់**

បន្ទាប់ពីបានអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់រួចហើយ ក្នុងថ្ងៃដដែល ឬនាថ្ងៃបន្ទាប់ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជួបប្រជុំគ្នាធ្វើការពិនិត្យលើការងារគ្រប់គ្រង និងដឹកនាំរបស់រដ្ឋបាលឃុំ សង្កាត់ ព្រមទាំងការពិនិត្យមើលទៅលើគម្រោង កម្មវិធីអភិវឌ្ឍន៍ និងគម្រោងសេវាកម្មនានាដែលនៅសេសសល់ពី ក្រុមប្រឹក្សាអាណត្តិចាស់ ដូចជា៖

**ក-ការពិភាក្សា និងពិនិត្យឡើងវិញលើគម្រោង កម្មវិធីអភិវឌ្ឍន៍ និងសេវាកម្មនានារបស់រដ្ឋបាលឃុំ សង្កាត់**

-ចំពោះគម្រោង កម្មវិធីអភិវឌ្ឍន៍ និងសេវាកម្មនានាដែលគាំទ្រដោយមូលនិធិឃុំ សង្កាត់ដែលបាន ធ្វើលទ្ធកម្មរួចហើយ តែមិនទាន់បានអនុវត្ត ឬកំពុងអនុវត្ត ឬកំពុងស្ថិតក្នុងកិច្ចសន្យា ក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិថ្មីត្រូវទទួលអនុវត្តបន្តនូវគម្រោង កម្មវិធីអភិវឌ្ឍន៍ និងសេវាកម្មទាំងនេះ រហូតដល់បញ្ចប់គម្រោង ឬ កិច្ចសន្យា។

-ចំពោះគម្រោង កម្មវិធីអភិវឌ្ឍន៍ និងសេវាកម្មនានាដែលក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិចាស់បាន លើកឡើង ហើយមិនទាន់បានធ្វើលទ្ធកម្ម ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មីត្រូវធ្វើការពិភាក្សា និងសម្រប សម្រួល ដើម្បីអនុវត្តបន្តរហូតដល់ពេលរៀបចំបាននូវផែនការអភិវឌ្ឍន៍របស់ខ្លួន។

-ចំពោះគម្រោង កម្មវិធីអភិវឌ្ឍន៍ និងសេវាកម្មនានាដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលនានាហើយដែលមិនស្ថិតក្នុងថវិការបស់ឃុំ សង្កាត់ ក្រុមប្រឹក្សា ឃុំ សង្កាត់ត្រូវធ្វើការពិភាក្សាជាមួយដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធ ដើម្បីបន្តអនុវត្តគម្រោងទាំងនោះ ស្របតាមគោលការណ៍របស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងសំណូមពររបស់ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលទាំងនោះ។

គម្រោង កម្មវិធីអភិវឌ្ឍន៍ និងគម្រោងសេវាកម្មទាំងនេះ ក្រោយពីក្រុមប្រឹក្សាឃុំ សង្កាត់ បានសម្រេចរួចត្រូវជូនព័ត៌មានជាបន្ទាន់ដល់អភិបាលរាជធានី ខេត្ត ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិល អំពីការសម្រេចចិត្តរបស់ខ្លួន និងត្រូវបិទផ្សាយភ្លាមនូវសេចក្តីសម្រេចនេះនៅលើក្តារព័ត៌មានរបស់រដ្ឋបាលឃុំ សង្កាត់។

ទន្ទឹមនឹងការពិភាក្សាពិនិត្យឡើងវិញនូវគម្រោង កម្មវិធីអភិវឌ្ឍន៍ និងគម្រោងសេវាកម្មនានាខាងលើ ក្រុមប្រឹក្សាឃុំ សង្កាត់ ក៏ត្រូវយកចិត្តទុកដាក់អនុវត្តការងារចាំបាច់បន្ទាន់មួយចំនួនទៀត ដូចខាងក្រោម ៖

-សម្របសម្រួល និងរៀបចំបែបបទស្នើតម្កល់គំរូហត្ថលេខាឡើងវិញទៅរតនាគារ និងធនាគារពាក់ព័ន្ធដែលមានគណនីរបស់ឃុំ សង្កាត់

-ធ្វើការពិនិត្យ ផ្ទៀងផ្ទាត់បញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិ សាច់ប្រាក់ដែលមានក្នុងបេឡារបស់ឃុំ សង្កាត់ សាច់ប្រាក់ដែលមាននៅក្នុងគណនីរបស់រដ្ឋបាលឃុំ សង្កាត់នៅរតនាគារនិងធនាគារនានា បញ្ជីបុគ្គលិក ឯកសារ និងកិច្ចសន្យានានា ដែលក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិចាស់បានចុះហត្ថលេខា ហើយដែលនៅមានសុពលភាពដើម្បីគ្រប់គ្រងកិច្ចសន្យានេះ រហូតដល់បញ្ចប់។

**ខ-ការពិភាក្សា និងពិនិត្យឡើងវិញលើគណៈកម្មាធិការ ឬគណៈកម្មការរបស់រដ្ឋបាលឃុំ សង្កាត់**

\+ គណៈកម្មាធិការ ឬគណៈកម្មការជាកាតព្វកិច្ចនានា: គណៈកម្មាធិការ ឬគណៈកម្មការជាកាតព្វកិច្ច គឺជាគណៈកម្មាធិការ ឬគណៈកម្មការដែលក្រុមប្រឹក្សាត្រូវបង្កើតឡើងដោយផ្អែកតាមលក្ខខណ្ឌតម្រូវនៃច្បាប់ អនុក្រឹត្យ និងលិខិតបទដ្ឋាននានា។ គណៈកម្មាធិការ ឬគណៈកម្មការជាកាតព្វកិច្ចនានាដែលបានបង្កើតឡើងតាមឃុំ សង្កាត់មានជាអាទិ៍៖ គណៈកម្មាធិការកសាងផែនការ និងថវិការបស់ឃុំ សង្កាត់ គណៈកម្មការលទ្ធកម្មរបស់ឃុំ សង្កាត់ និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ។

ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មីត្រូវពិនិត្យមើលឡើងវិញនូវសមាជិកភាពគណៈកម្មាធិការ ឬគណៈកម្មការដែលជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់តែប៉ុណ្ណោះ។ ក្នុងករណីសមាជិកភាពគណៈកម្មាធិការ ឬគណៈកម្មការរូបណាមួយជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលមិនបានជាប់ឆ្នោតជាបន្តទៀត ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មី ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាថ្មីដែលជាប់ឆ្នោតឲ្យជំនួសស្របទៅតាមនីតិវិធី តាមរយៈការចេញសេចក្តីសម្រេចរបស់ឃុំ សង្កាត់។

\+ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ : ឃុំ សង្កាត់ទាំងឡាយណាដែលមានគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ត្រូវបន្តការងាររបស់គណៈកម្មាធិការនេះជាបន្តទៅទៀត ដោយគ្រាន់តែពិនិត្យសមាជិកភាពគណៈកម្មាធិការនេះ ដែលជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដូចគណៈកម្មាធិការជាកាតព្វកិច្ចរបស់ឃុំ សង្កាត់ដែរ។

\+ ជនបង្គោលទទួលបន្ទុកស្ត្រី និងកុមារ : ឃុំ សង្កាត់ត្រូវពិនិត្យមើលស្ត្រីជនបង្គោលទទួលបន្ទុកស្ត្រី និងកុមាររបស់ឃុំ សង្កាត់ តាមករណីពីរយ៉ាងដូចខាងក្រោម៖

-ករណីស្ត្រីជាជនបង្គោលទទួលបន្ទុកស្ត្រី និងកុមារជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិចាស់ដែលបានជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងអាណត្តិថ្មីបន្តទៀត សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់រូបនោះត្រូវបន្តទទួលជាជនបង្គោលទទួលបន្ទុកស្ត្រី និងកុមាររបស់ឃុំ សង្កាត់បន្តទៀត។ ប៉ុន្តែប្រសិនបើស្ត្រីជាជនបង្គោលរូបនោះ មិនបានជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់បន្តទៀតទេ ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មី ត្រូវធ្វើការជ្រើសរើសស្ត្រីជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់០១រូប ឲ្យទទួលជាជនបង្គោលទទួលបន្ទុកស្ត្រី និងកុមារជំនួស ស្របទៅតាមនីតិវិធី តាមរយៈការចេញសេចក្ដីសម្រេចរបស់ឃុំ សង្កាត់។ ក្នុងករណីដែលក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មីមិនមានស្ត្រីជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សា ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មី ត្រូវធ្វើការជ្រើសរើសស្ត្រីមួយរូបនៅក្នុងឃុំ សង្កាត់របស់ខ្លួនឲ្យទទួលជាជនបង្គោលទទួលបន្ទុកស្ត្រី និងកុមារក្នុងឃុំ សង្កាត់របស់ខ្លួនឲ្យបានសមស្របតាមនីតិវិធី។

-ករណីឃុំ សង្កាត់អាណត្តិចាស់មានស្ត្រីជាជនបង្គោលទទួលបន្ទុកស្ត្រី និងកុមារដែលមិនមានជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ប៉ុន្តែក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មីមានស្ត្រីមួយរូបជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នោះ ត្រូវធ្វើការជ្រើសរើសស្ត្រីដែលជាសមាជិក្រុមប្រឹក្សាឃុំ សង្កាត់នោះឲ្យទទួលជាជនបង្គោលទទួលបន្ទុកស្ត្រី និងកុមារឲ្យបានស្របតាមនីតិវិធី។ ប្រសិនបើ ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មីមានស្ត្រីលើសពីចំនួន០១រូបជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សា ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មីនោះត្រូវធ្វើការពិភាក្សា និងសម្រេចជ្រើសរើសស្ត្រីតែមួយរូបប៉ុណ្ណោះ ឲ្យទទួលជាជនបង្គោលទទួលបន្ទុកស្ត្រី និងកុមារឲ្យបានស្របតាមនីតិវិធី។

+គណៈកម្មាធិការ ឬគណៈកម្មការចំពោះកិច្ចនានា : គណកម្មាធិការ ឬគណៈកម្មការចំពោះកិច្ចគឺជាគណៈកម្មាធិការ ឬគណៈកម្មាការដែលក្រុមប្រឹក្សាឃុំ សង្កាត់ បង្កើតឡើងដើម្បីជួយការងារតាមការចាំបាច់របស់ខ្លួន។ គណៈកម្មាធិការ ឬគណៈកម្មការប្រភេទនេះ ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មីត្រូវធ្វើការពិនិត្យមើលឡើងវិញ និងវាយតម្លៃអំពីភាពចាំបាច់ ឬមិនចាំបាច់នៃគណៈកម្មាធិការ ឬគណៈកម្មការទាំងនោះក្នុងការជួយចាត់ចែងការងាររបស់ខ្លួនតាមការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ស្របទៅតាមនីតិវិធី។ ក្នុងករណីដែលក្រុមប្រឹក្សាអាណត្តិថ្មីយល់ឃើញថា គណៈកម្មាធិការ ឬគណៈកម្មការមួយមានភាពចាំបាច់ក្រុមប្រឹក្សាអាណត្តិថ្មីអាចបន្តនិរន្តភាពការងាររបស់គណៈកម្មាធិការ ឬគណៈកម្មការទាំងនោះជាបន្តទៀតដោយគ្រាន់តែធ្វើការផ្លាស់ប្តូរសមាសភាពគណៈកម្មាធិការ ឬគណៈកម្មការដែលជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលមិនជាប់ឆ្នោតដោយដាក់ជំនួសសមាជិកក្រុមប្រឹក្សាថ្មីដែលជាប់ឆ្នោត ឬចាំបាច់ត្រូវធ្វើការរៀបចំសមាសភាពគណៈកម្មាធិការ ឬគណៈកម្មការជាថ្មីឡើងវិញទាំងស្រុង ដោយផ្អែកទៅតាមការពិភាក្សាសម្រេច របស់ក្រុមប្រឹក្សាឃុំ សង្កាត់។ ចំពោះគណៈកម្មាធិការ ឬគណៈកម្មការទាំងឡាយណាដែលក្រុមប្រឹក្សាយល់ឃើញថាមិនចាំបាច់ ក្រុមប្រឹក្សាឃុំ សង្កាត់អាចរំលាយគណៈកម្មាធិការ ឬគណៈកម្មការនោះចោលបានទៅតាមការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។

**គ-ការអនុវត្តច្បាប់ និងលិខិតបទដ្ឋាននានា**

ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មីត្រូវអនុវត្តឲ្យបានត្រឹមត្រូវទៅតាមច្បាប់ និងលិខិតបទដ្ឋាននានាដែលមានជាធរមាន ក្នុងការចាត់ចែងការងារនៅក្នុងឃុំ សង្កាត់របស់ខ្លួន។

ក្រុមប្រឹក្សាអាណត្តិថ្មី ត្រូវបន្តអនុវត្តដីកា សេចក្តីសម្រេច និងលិខិតបទដ្ឋាននានារបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិចាស់ ឲ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាព រហូតដល់មានដីកា សេចក្តីសម្រេច និងលិខិតបទដ្ឋានថ្មីមកជំនួស សមស្របតាមនីតិវិធី ឬត្រូវបានកែសម្រួលឲ្យបានសមស្របតាមនីតិវិធី។

សេចក្តីណែនាំលេខ០០៦ ស.ណ.ន ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៧ របស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំកិច្ចប្រជុំលើកដំបូងដើម្បីប្រកាសសុពលភាពសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រកាសឈ្មោះប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង ព្រមទាំងការចាប់ផ្តើមបំពេញការងារបន្ទាប់កិច្ចប្រជុំលើកដំបូង ត្រូវចាត់ទុកជានិរាករណ៍។

ទទួលបានសេចក្តីណែនាំនេះ រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ព្រមទាំងអង្គភាពពាក់ព័ន្ធចំណុះទីស្តីការក្រសួងមហាផ្ទៃ ត្រូវទទួលខុសត្រូវចាត់ចែងផ្សព្វផ្សាយ និងអនុវត្តសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ [illegible] ឆ្នាំ២០១៧

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- អង្គភាពប្រឆាំងអំពើពុករលួយ
- លេខាធិការដ្ឋាន គ.ជ.អ.ប

  *(ដើម្បីជូនជ្រាប)*
- ឯកសារ កាលប្បវត្តិ